# ម៉ាន់ ឡុង ស៊ូ ឯ.ក
# MANN LONG SHOES CO., LTD
# 万龙鞋业有限公司

ក្រុមហ៊ុន ម៉ាន់ ឡុង ស៊ូ ឯ.ក MANN LONG SHOES CO.,LTD KINGDOM OF CAMBODIA

## កិច្ចព្រមព្រៀងស្តីអំពីព្យួរកិច្ចសន្យាការងារ
## ចាប់ពីថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២២ ដល់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២

កិច្ចព្រមព្រៀងស្តីអំពីព្យួរការងារចាប់ពីថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២២ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ បានធ្វើឡើងនៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០២២ រវាងរោងចក្រហៅថាភាគី"ក"តំណាងអោយនិយោជក ជាមួយតំណាងកម្មករ សហជីពប្រធានក្រុមប្រចាំរោងចក្រហៅថាភាគី "ខ"

ភាគីទាំងពីរបានយល់ព្រមលើកិច្ចព្រមព្រៀងមានដូចខាងក្រោម៖

១. ភាគី"ក"ត្រូវព្យួរកិច្ចសន្យាការងារកម្មករមួយចំនួន ចាប់ពីថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២២ ដល់ ថ្ងៃទី៣១ខែធ្នូ ឆ្នាំ២០២២។

២. ភាគី"ក"និងផ្តល់ចំនួននិងឈ្មោះកម្មករដែលត្រូវព្យួរការងារដល់ផ្នែកនីមួយដែលត្រូវព្យួរការងារ។

៣. ភាគី"ក"ព្យួរកិច្ចសន្យាការងារចំពោះកម្មករដែលធ្វើការនៅផ្នែកតុកាត់ ,ក្រុមជា ,ជាន់ពុម្ព ,ក្រុមដេរ 2 , ក្រុមដេរ 3 , ក្រុមដេរ 5 , ក្រុមដេរ 6 ,ក្រុមដេរ 8,ក្រុមដេរ 9 ,ក្រុមបំរុង , ខ្សែទឹកហូរ ,ខ្សែទឹកហូរ 2 ,QC-A/B,QC-C,វត្ថុធាតុដើម , ផលិតផល ,ផ្នែកឈូសបាត ,ជាងម៉ាស៊ីន ចាប់ពីថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២២ ដល់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២។

៤. កម្មករដែលព្យួរការងារត្រូវទទួលបានប្រាក់ ៧ដុល្លា ក្នុង១ខែ សំរាប់ការស្នាក់នៅនិងធ្វើដំណើរដែលច្បាប់បានកំណត់។កម្មករត្រូវមកទទួលប្រាក់នេះ នៅថ្ងៃបើកប្រាក់ខែលើកទី២ ជារាងរាល់ខែនៅថ្ងៃទី១០។

៥. កម្មករមិនទទួលបានប្រាក់ឈ្នួលប្រចាំថ្ងៃ ប្រាក់រង្វាន់ ប្រាក់ឧបត្ថម ប្រាក់មុខងារ និងផលប្រយោជន៍ផ្សេងទៀតដែលមិនបានតម្រូវដោយច្បាប់នៅក្នុងកំឡុងពេលព្យួរកិច្ចសន្យាការងារ។

៦. ភាគី"ក"ព្យួរកិច្ចសន្យាការងាររបស់កម្មករដោយរោងចក្រអត់មានការកម្ម៉ង់ទិញពីអតិថិជន។

កិច្ចព្រមព្រៀងនេះធ្វើឡើងនៅចំពោះមុខតំណាងកម្មករ សហជីព និងប្រធានក្រុម បានឯកភាពទាំងសងខាង និងមិនមានការបង្ខិតបង្ខំពីភាគីណាមួយឡើយ។

កំពង់ចាម ថ្ងៃទី២១ ខែតុលា ឆ្នាំ២០២២

ហត្ថលេខា អ្នកតំណាងខាងភាគី"ក"

ក្រុមហ៊ុន
ម៉ាន់ ឡុង ស៊ូ ខ.ក
MANN LONG SHOES
CO.,LTD
KINGDOM OF CAMBODIA

ហត្ថលេខានិងស្នាមមេដៃរបស់ភាគី"ខ"(តំណាងកម្មករ សហជីព និងប្រធានក្រុម)